ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថាបើក
## លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីបើកសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៤ ស្តីពី
## "តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា"
### សណ្ឋាគារសូហ្វីតែល ភូគីត្រា ភ្នំពេញ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៧

**សូមគោរព ៖**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ថ្ងៃនេះ តាងនាម ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ខ្ញុំមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួមក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា។ នេះគឺជាលើកទី៤ហើយ ដែលសន្និសីទម៉ាក្រូសេដ្ឋកិច្ច ត្រូវបានរៀបចំឡើងក្នុងគោលបំណងរួមចំណែកពង្រឹងនិងអភិវឌ្ឍ សមត្ថភាពស្រាវជ្រាវ និងផ្តល់ជាវេទិកាពិភាក្សាលើប្រធានបទសំខាន់ៗចំពោះសេដ្ឋកិច្ចនិងប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា។

កាលពីឆ្នាំ២០១៦ កន្លងទៅ ប្រធានបទនៃសន្និសីទរបស់យើងផ្តោតទៅលើ "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា៖ កាលានុវត្តភាព និងហានិភ័យ"។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការរួមចំណែកក្នុងការស្រាវជ្រាវនិងការពិភាក្សាលើប្រធានបទដ៏មានសារៈសំខាន់នេះ។ ខ្ញុំសង្កេតឃើញថា ពីមួយឆ្នាំទៅមួយឆ្នាំការចូលរួមក្នុងការស្រាវជ្រាវបានកើនឡើងស្របពេលដែលវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរីកចម្រើនឥតឈប់ឈរ ហើយក៏រំលេចនូវប្រធានបទកាន់តែគួរឱ្យចាប់អារម្មណ៍ជាច្រើនផងដែរ។

នៅឆ្នាំ២០១៧នេះ ដោយយល់ឃើញអំពីសារៈសំខាន់ និងការរីកចម្រើនយ៉ាងរហ័សនៃការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងវិស័យហិរញ្ញវត្ថុ (Fintech) និងដើម្បីរួមចំណែកក្នុងគោលនយោបាយលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ សន្និសីទម៉ាក្រូសេដ្ឋកិច្ចឆ្នាំនេះ ផ្តោតសំខាន់លើប្រធានបទស្តីពី "តួនាទីរបស់បច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ"។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងមកពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដែលបានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមក្នុងសន្និសីទរបស់យើងនាពេលនេះ។ ខ្ញុំមានជំនឿថា វត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងញ៉ាំងឱ្យសន្និសីទនេះកាន់តែមានភាពឱឡារិក និងទទួលបានផ្លែផ្កា គួរជាទីមោទនៈ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ស្របពេលដែលបច្ចេកវិទ្យាបានវិវត្តយ៉ាងឆាប់រហ័ស បច្ចេកវិទ្យាថ្មីៗត្រូវបានយកមកប្រើប្រាស់ក្នុងវិស័យហិរញ្ញវត្ថុ ហើយបានបង្កើតឱ្យមានពាក្យថា "FinTech" ឬ "បច្ចេកវិទ្យាហិរញ្ញវត្ថុ"។ "បច្ចេកវិទ្យាហិរញ្ញវត្ថុ" មិនទាន់មាននិយមន័យច្បាស់លាស់នៅឡើយទេ ប៉ុន្តែបើយោងតាមឯកសារស្រាវជ្រាវរបស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) នៅឆ្នាំ ២០១៧ ស្តីពីកាលានុវត្តភាពរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុ បានកំណត់និយមន័យថា "FinTech" ជាការច្នៃប្រឌិតនៃបច្ចេកវិទ្យាដែលធ្វើឱ្យមានការវិវត្តនៅក្នុងវិស័យហិរញ្ញវត្ថុ។ បច្ចុប្បន្ន ផលិតផលសំខាន់ៗដែលកើតចេញពី FinTech រួមមាន៖ ប្រព័ន្ធទូទាត់តាមទូរស័ព្ទ (mobile payment), ប្រព័ន្ធផ្តល់កម្ចីដោយមិនមានអន្តរការិយកម្ម (Peer 2 Peer), ប្រព័ន្ធផ្តល់សេវាប្រឹក្សានិងការជួញដូរតាមអនឡាញ (Online), Sandbox, Blockchains, Cryptocurrencies, ការអភិវឌ្ឍ software Artificial Intelligence (AI) ជាដើម។

បច្ចេកវិទ្យាហិរញ្ញវត្ថុបានវិវត្តនិងបង្កើតផលិតផលនិងសេវាជាច្រើន ដើម្បីឆ្លើយតបនឹងតម្រូវការអតិថិជន។ ការលេចឡើងនូវការច្នៃប្រឌិតយ៉ាងឆាប់រហ័ស ខណៈពេលធនាគារមានប្រតិបត្តិការបែបប្រពៃណីចាប់ផ្តើមមានបញ្ហាប្រឈមមួយចំនួនរួមមាន ថ្លៃប្រតិបត្តិការមានតម្លៃខ្ពស់, មានការច្នៃប្រឌិតទាបទាក់ទងនឹងបច្ចេកវិទ្យា, អតិថិជនមិនសូវមានប្រតិបត្តិការជាមួយធនាគារ ជាដើម។ ហេតុនេះ ធនាគារដែលមានប្រតិបត្តិការបែបប្រពៃណីបានបង្កើនផលិតផលនិងសេវាបន្ថែមទៀត ដោយវិវត្តទៅរកធនាគារឌីជីថល ដើម្បីផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែប្រសើរជាងមុន។ ទោះយ៉ាងណា ខ្ញុំសូមគូសបញ្ជាក់ផងដែរអំពីគុណសម្បត្តិនិងគុណវិបត្តិនៃភាពច្នៃប្រឌិតផ្នែកហិរញ្ញវត្ថុ។ បច្ចេកវិទ្យាហិរញ្ញវត្ថុបានផ្តល់គុណសម្បត្តិជាច្រើន តាមរយៈការជំរុញឱ្យសេវាហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព ចំណាយតិច ឆាប់រហ័ស សមាហរណកម្មខ្ពស់ លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងគាំទ្រកំណើនសេដ្ឋកិច្ច។ ទន្ទឹមនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុក៏បង្កឱ្យមានហានិភ័យប្រតិបត្តិការផងដែរ (រួមមានហានិភ័យ Cyber, ហានិភ័យនៅក្នុងក្រុមហ៊ុនតតិយភាគីដែលមិននៅក្រោមច្បាប់, ការចែងមិនច្បាស់លាស់នៅក្នុងច្បាប់), ហានិភ័យកម្រិតមីក្រូនិងម៉ាក្រូ និងកង្វះខាតទិន្នន័យក្នុងការវាយតម្លៃហានិភ័យ។ ទន្ទឹមនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុក៏បង្កឱ្យមានបញ្ហាប្រឈមចម្បងៗដែរ រួមមាន៖ i/- ការអនុវត្តគោលនយោបាយរូបិយវត្ថុមិនសូវមានប្រសិទ្ធភាព ដោយសារឧបករណ៍គោល-

នយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលមិនមានឥទ្ធិពលលើស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ (Nonbank) និងការវិវត្តព្រមទាំងការផ្លាស់ប្តូរសមាសធាតុនៃរូបិយវត្ថុទូទៅ ii/- ការគ្រប់គ្រងនៃការវិវត្តហានិភ័យរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុទៅលើស្ថិរភាពហិរញ្ញវត្ថុ និង iii/- ការធ្វើឱ្យមានតុល្យភាពរវាងគោលដៅបរិយាប័ន្នហិរញ្ញវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ។

ទោះយ៉ាងណា ដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ជាច្រើន បានអនុញ្ញាតឱ្យបច្ចេកវិទ្យាហិរញ្ញវត្ថុប្រើប្រាស់ក្នុងប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួន ទន្ទឹមនឹងការតាមដានដោយប្រុងប្រយ័ត្នលើវឌ្ឍនភាពរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុនិងផលប៉ះពាល់ ក្នុងខណៈដែលបទប្បញ្ញត្តិនៅពុំទាន់មានការគ្រប់គ្រងនៅឡើយស្តីពីការប្រើប្រាស់សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុ។

នៅកម្ពុជា ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធទូទាត់ផ្អែកលើបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗនិងបានអនុញ្ញាតឱ្យមានការផ្តល់សេវាបច្ចេកវិទ្យាហិរញ្ញវត្ថុដោយគ្រឹះស្ថានធនាគារនិងហរិញ្ញវត្ថុផងដែរ។ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រព័ន្ធទូទាត់រាយនៅឆ្នាំ២០១២ សម្រាប់ផាត់ទាត់មូលប្បទានបត្រ និងបញ្ជាផ្ទេរឥណទាន។ ប្រព័ន្ធសម្រាប់សេវាទូទាត់រហ័សបានដាក់ឱ្យដំណើរការនៅឆ្នាំ២០១៦ សម្រាប់សម្រួលដល់ការទូទាត់ភ្លាមៗនូវរាល់ការផ្ទេរមូលនិធិ។ ប្រព័ន្ធ Cambodian Shared Switch (CSS) ទើបតែត្រូវបានដាក់ឱ្យដំណើរការនៅខែតុលា ឆ្នាំ២០១៧នេះ សម្រាប់សម្រួលដល់ប្រតិបត្តិការម៉ាស៊ីន ATM និងម៉ាស៊ីន POS។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាក៏កំពុងសិក្សាពីលទ្ធភាពក្នុងការប្រើប្រាស់រូបិយប័ណ្ណឌីជីថលផងដែរ សម្រាប់ការទូទាត់នៅក្នុងទីផ្សារអន្តរធនាគារ។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការផ្តល់សេវាហិរញ្ញវត្ថុផងដែរ តាមរយៈមធ្យោបាយនៃការទូទាត់ផ្សេងៗដូចជា ការជំរុញការប្រើប្រាស់ប័ណ្ណឥណពន្ធនិងប័ណ្ណឥណទាន ប័ណ្ណ Prepaid តាមម៉ាស៊ីន ATM ម៉ាស៊ីន POS និងម៉ាស៊ីន Kiosk សេវាទូទាត់ធនាគារចល័ត និងអ៊ីនធើណែត។ គ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុក៏ត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាទូទាត់សម្រាប់ការផ្ទេរប្រាក់ឆ្លងប្រទេស ហើយបាននិងកំពុងរួមចំណែកកាត់បន្ថយចំណាយផ្ទេរ និងទទួលបានមូលនិធិភ្លាមៗ។ ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុទាំងនេះបានរួមចំណែកគាំទ្របរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ដើម្បីជំរុញបរិយាប័ន្នហិរញ្ញវត្ថុនិងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តយន្តការមួយចំនួនដូចជា៖ i/- ពង្រឹងប្រព័ន្ធសុវត្ថិភាពប្រឆាំងនឹងឧក្រិដ្ឋកម្មបច្ចេកវិទ្យា ii/-បន្តលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ តាមរយៈការធ្វើយុទ្ធនាការ"តោះ! និយាយពីលុយ" iii/- អភិវឌ្ឍយន្តការចែករំលែកព័ត៌មានឥណទាន iv/- ពង្រឹងកិច្ចការពារអតិថិជន, បង្កើតប្រព័ន្ធ Hotline ក្នុងការឆ្លើយតបនិងដោះស្រាយបញ្ហាដោយផ្ទាល់ ជូនសារធារណជន v/- ពង្រឹងច្បាប់

និងបទប្បញ្ញត្តិ និង vi/- ជំរុញកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធដើម្បីពង្រឹងគុណភាពទិន្នន័យ ។

ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីបញ្ហានេះ ប្រធានបទចំនួន៣នឹងយកមកពិភាក្សា៖ ការប្រើប្រាស់ទូរស័ព្ទឆ្លាតវៃនិងបរិយាប័ន្នហិរញ្ញវត្ថុ, ដំណើរអភិវឌ្ឍនៃបច្ចេកវិទ្យានិងផលប៉ះពាល់ក្នុងការទទួលបានសេវាហិរញ្ញវត្ថុ និងតួនាទីបច្ចេកវិទ្យាក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ។ តាមរយៈសន្និសីទម៉ាក្រូសេដ្ឋកិច្ចរបស់យើងនាថ្ងៃនេះ ខ្ញុំជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងបានស្វែងយល់បន្ថែមពីបញ្ហាចម្បងៗ ដែលភាពច្នៃប្រឌិតផ្នែកហិរញ្ញវត្ថុនិងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ដែលជាលទ្ធផលនៃការស្រាវជ្រាវរបស់វាគ្មិនយើង ។ លើសពីនេះ លទ្ធផលនៃការស្រាវជ្រាវនិងកិច្ចពិភាក្សានាពេលនេះ នឹងផ្តល់ជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំគោលនយោបាយប្រកបដោយភាពគ្រប់ជ្រុងជ្រោយ សំដៅរួមចំណែកធានាឱ្យបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់សូមមានសុខភាពល្អ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច ។ ខ្ញុំសូមប្រកាសបើកសន្និសីទនេះចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**